# សេចក្តីសង្ខេបអំពីការងារ
# អ្នកគ្រប់គ្រងកម្មវិធី ផ្នែកអប់រំសិល្បៈនិងវប្បធម៌នៅក្នុងគ្រឹះស្ថានអប់រំរដ្ឋ

## ក. ព័ត៌មានទូទៅ

| | |
|---|---|
| **មុខតំណែង** : | អ្នកគ្រប់គ្រងកម្មវិធី ផ្នែកអប់រំសិល្បៈនិងវប្បធម៌នៅក្នុងគ្រឹះស្ថានអប់រំរដ្ឋ |
| **កន្លែងការងារ** : | ភ្នំពេញ, កម្ពុជា (តម្រូវឲ្យចុះធ្វើការតាមខេត្ត) |
| **តំណែងនេះស្ថិតក្រោម** : | នាយកកម្មវិធី |
| **ទទួលបានការជួយពី** : | អ្នកប្រឹក្សាកម្មវិធីអប់រំសិល្បៈ, អ្នកតំណាងគោលនយោបាយអប់រំសិល្បៈ, អ្នកសម្របសម្រួលកម្មវិធី |

## ខ. សាវតា

សិល្បៈខ្មែរអមតៈ កំពុងអនុវត្តកម្មវិធីរយៈពេល ៥ ឆ្នាំ របស់ខ្លួន ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, និងអង្គការយូណេស្កូ ដើម្បីសាកល្បងអនុវត្តគម្រោងជាគម្រូមួយ ក្នុងការផ្តល់ការអប់រំសិល្បៈប្រកបដោយភាពច្នៃប្រឌិតនៅតាមគ្រឹះស្ថានអប់រំ ទូទាំងប្រទេសកម្ពុជា។

## គ. អំពីមុខដំណែង

អ្នកគ្រប់គ្រងកម្មវិធី គឺជាសមាជិកសំខាន់ម្នាក់ក្នុងចំណោមបុគ្គលិកទាំងឡាយ ដែលមានទំនួលខុសត្រូវខ្ពស់ក្នុងការធ្វើឲ្យគម្រោងសាកល្បងនេះ មានដំណើរការអភិវឌ្ឍន៍ទៅមុខ។ យុទ្ធសាស្រ្តសម្រាប់អនុវត្តគម្រោង នឹងត្រូវបានផ្តល់ជូនដោយអ្នកប្រឹក្សាផ្នែកអប់រំសិល្បៈ (រួមផ្សំនឹងយោបល់ពីក្រុមការងាររបស់គម្រោងផងដែរ) ហើយអ្នកគ្រប់គ្រងកម្មវិធី មានតួនាទីយកយុទ្ធសាស្រ្តទាំងនោះមកបំលែងឲ្យទៅជាសកម្មភាពជាក់ស្តែង។

គម្រោងសាកល្បងនេះមានរយៈពេល ៥ ឆ្នាំ (ផែនការ ១ ឆ្នាំ ត្រូវបានបំពេញរួចហើយ) ហើយគម្រោងទាំងមូលនេះ ចែកចេញជា ២ ផ្នែកធំៗ។ ផ្នែកទី១ គឺការធ្វើការជាមួយ ក្រសួងអប់រំ យុវជន និងកីឡា លើការអភិវឌ្ឍន៍កម្មវិធីសិក្សា និងការបណ្តុះបណ្តាលគ្រូថ្នាក់ជាតិ។ ផ្នែកទី២ គឺការធ្វើការជាមួយសិល្បករ និងដៃគូនានា ដើម្បីអភិវឌ្ឍមធ្យោបាយដ៏មានប្រសិទ្ធិភាពក្នុងការផ្តល់សកម្មភាពសិល្បៈនិងវប្បធម៌នានា ដល់សិស្សានុសិស្ស ដែលអាចរួមផ្សំឬបន្ថែម ទៅនឹងអ្វីដែលពួកគេបានរៀនតាមរយៈកម្មវិធីសិក្សាថ្នាក់ជាតិ។ សម្រាប់ផ្នែកទី ២ នេះ ពួកយើងកំពុងតែសាក

ល្បងគំនិតក្នុងការដំណើរការមជ្ឈមណ្ឌល ដែលអាចបម្រើការបានលើសពី ១ សាលា ដែលជាកន្លែង ដែលសិស្សានុសិស្ស អាចទទួលបទពិសោធន៍តាមរយៈបាបកថា សិក្ខាសាលា ក្លិប និងការសម្ដែងឬពិព័ណ៌។ ពួកយើងមានបំណងបើកមជ្ឈមណ្ឌលចំនួន ៦ ក្នុងអំឡុងនៃគម្រោងសាកល្បងនេះ ហើយក្នុងចំណោមមជ្ឈមណ្ឌលទាំង ៦ នេះ មានជម្លមណ្ឌលមួយ (មជ្ឈមណ្ឌលវិទ្យាល័យព្រះស៊ីសុវត្ថិ ក្នុងក្រុងភ្នំពេញ) ដែលសិល្បៈខ្មែរអមតៈ ជាអ្នកគ្រប់គ្រងផ្ទាល់។

ការអប់រំសិល្បៈ គឺជាវិស័យថ្មីមួយ នៅក្នុងប្រទេសកម្ពុជា ដូច្នេះពួកយើងកំពុងស្វែងរកមនុស្សម្នាក់ ដែលមានចំណាប់អារម្មណ៍និងចំណង់ចំណូលចិត្តខ្ពស់នៅក្នុងវិស័យមួយនេះ ហើយដែលចេះមានភាពបត់បែន ក្នុងការអនុវត្តគម្រោង។ អ្នកគ្រប់គ្រងកម្មវិធី ត្រូវមានទំនុកចិត្តលើការងាររបស់ខ្លួនដូចជា ការគ្រប់គ្រងផែនការ ថវិកា និងសមាជិកក្រុម ដើម្បីឲ្យធនធានទាំងនោះត្រូវបានប្រើប្រាស់ ប្រកបដោយប្រសិទ្ធិភាពខ្ពស់។ អ្នកដែលពួកយើងកំពុងត្រូវការនោះ ក៏គួរតែជាអ្នកដែលធ្លាប់មានបទពិសោធន៍ការងារ នៅក្នុងប្រព័ន្ធអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងជាអ្នកដែលមានការឲ្យតម្លៃទៅលើវប្បធម៌និងសិល្បៈកម្ពុជា ព្រមទាំងភាពច្នៃប្រឌិតផងដែរ។

## ឃ. ទំនួលខុសត្រូវ

### ការអភិវឌ្ឍន៍និងការអនុវត្តកម្មវិធី

- អភិវឌ្ឍនិងត្រួតពិនិត្យផែនការការងារនិងថវិកាប្រចាំឆ្នាំ
- សម្របសម្រួលធនធាន ដែលត្រូវការសម្រាប់ការអនុវត្តកម្មវិធី
- ដឹកនាំនិងត្រួតពិនិត្យក្រុមការងារនៃកម្មវិធី ដើម្បីអនុវត្តគម្រោង
- បង្កើតលក្ខន្តិកៈការងារឲ្យបានច្បាស់លាស់ជាមួយដៃគូអនុវត្តគម្រោង
- បង្កើតនិងរក្សាទំនាក់ទំនងល្អជាមួយបណ្ដាស្ថាប័នសិល្បៈនិងវប្បធម៌ជាតិនិងអន្តរជាតិ
- គាំទ្រគណៈគ្រប់គ្រងជាន់ខ្ពស់និងក្រុមប្រឹក្សាភិបាល តាមរយៈការផ្ដល់ព័ត៌មាននិងការចូលរួមជាគំនិត ដើម្បីអភិវឌ្ឍគម្រោងឲ្យបានកាន់តែប្រសើរ

### ការតស៊ូមតិ គោលនយោបាយ និងការបង្កើតសហព័ន្ធ

- គាំទ្រដល់អ្នកតំណាងគោលនយោបាយ និងអ្នកប្រឹក្សាផ្នែកអប់រំសិល្បៈ ដើម្បីធ្វើការសម្រេចចិត្តនានា ទាក់ទងទៅនឹងការចូលរួមរបស់សិល្បៈខ្មែរអមតៈ នៅក្នុងកំណែតម្រង់និងការអភិវឌ្ឍគោលនយោបាយជាតិ
- ធ្វើការយ៉ាងជិតជាមួយអ្នកតំណាងគោលនយោបាយ ដើម្បីឲ្យដឹងពីភាពរីកចម្រើនលើការអភិវឌ្ឍកម្មវិធីសិក្សានិងកម្មវិធីបណ្ដុះបណ្ដាលគ្រូថ្នាក់ជាតិ

- ចូលរួមកិច្ចប្រជុំអនុគណៈកម្មការនិងកិច្ចប្រជុំនានាដែលពាក់ព័ន្ធនឹងគម្រោង ទៅតាមតម្រូវការ
- ធ្វើការទំនាក់ទំនងជាមួយដៃគូនិងអ្នកពាក់ព័ន្ធនានា ទៅតាមតម្រូវការ

**ការគាំទ្រដល់កម្មវិធីសិក្សានិងគ្រូ** :

- សម្របសម្រួលកិច្ចសហការជាមួយអង្គការសាលាជំនាន់ថ្មី ទាក់ទងនិងការបង្កើតនិងការអនុវត្តកម្មវិធិសិក្សាសិល្បៈនិងវប្បធម៌ ទូទាំងគ្រឹះស្ថានអប់រំរដ្ឋ
- គាំទ្រនិងផ្តល់យោបល់ដល់គ្រូសិល្បៈនិងគ្រូដែលជាសិល្បករ នៅពេលពួកគេបង្កើតនិងអនុវត្តកម្មវិធីសិក្សានិងកិច្ចតែងការរបស់ពួកគេ
- សម្របសម្រួល រវាងកម្មវិធីសិក្សាបន្ថែមនិងគោលការណ៍នៃកម្មវិធី ដើម្បីរៀបចំធនធាននិងចងក្រងឯកសារ ទុកសម្រាប់គ្រូនិងអ្នកដទៃទៀតដែលកំពុងធ្វើការលើកម្មវិធីសិក្សា យកមកប្រើប្រាស់បាន

**កម្មវិធីសិក្សាបន្ថែមនិងសហកម្មវិធីសិក្សា**

- មើលការខុសត្រូវអ្នកសម្របសម្រួលគម្រោង នៅក្នុងការបង្កើតផែនការងារនិងគោលដៅការងារសម្រាប់ការអនុវត្តសកម្មភាពសិល្បៈនិងវប្បធម៌ នៅក្នុងមជ្ឈមណ្ឌលវប្បធម៌ទាំង ៦ ដែលពួកយើងមានបំណងដាក់ឲ្យដំណើរការនៅក្នុងគម្រោងសាកល្បង ៥ ឆ្នាំនេះ ជាពិសេស មជ្ឈមណ្ឌល នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ដែលគ្រប់គ្រងដោយអង្គការសិល្បៈខ្មែរអមតៈផ្ទាល់
- ជួយដល់ដំណើរការនៃការគាំទ្រដល់មជ្ឈមណ្ឌលទាំងអស់ ដើម្បីរៀបចំកម្មវិធីសិក្សាបន្ថែមដែលប្រកបដោយផ្លែផ្កា
- ជួយដល់អ្នកប្រឹក្សាកម្មវិធីអប់រំសិល្បៈ ដើម្បីបង្កើតយុទ្ធសាស្ត្រសម្រាប់ដាក់ឲ្យដំណើរការនូវមជ្ឈមណ្ឌលទាំង ៦ នៅក្នុងអំឡុងពេលគម្រោង (សព្វថ្ងៃ មជ្ឈមណ្ឌលចំនួន ២ បានចាប់ផ្តើមការងាររបស់ខ្លួនហើយ) ដែលនឹងរួមបញ្ចូលការបង្កើតគម្រូភាពនៃការផ្តោតលើកម្មវិធី ការផ្តល់មូលនិធិ និងភាពជាដៃគូ ឲ្យមជ្ឈមណ្ឌលនីមួយៗ
- វាយតម្លៃសកម្មភាពកម្មវិធី និងវិធីសាស្ត្រផ្សេងៗ ដែលយកមកអនុវត្ត ព្រមទាំងកែតម្រូវលើការអនុវត្តផែនការយុទ្ធសាស្ត្រ

**លក្ខណៈទូទៅ** :

- គ្រប់គ្រងនិងគាំទ្របុគ្គលិកកម្មវិធីអប់រំទាំងអស់
- គាំទ្រការរកមូលនិធិសម្រាប់ទ្រទ្រង់កម្មវិធី
- ចូលរួមជាប្រចាំនៅក្នុងកិច្ចប្រជុំក្រុមការងារ និងកិច្ចប្រជុំបុគ្គលិកប្រចាំឆ្នាំ

- ចូលរួមគំនិតសម្រាប់ការអភិវឌ្ឍនិងការពង្រឹងកម្មវិធី
- ចូលរួមគាំទ្រក្នុងកម្មវិធីផ្សេងៗនិងផែនការយុទ្ធសាស្ត្ររបស់អង្គការសិល្បៈខ្មែរអមតៈ
- អនុវត្តតាមគោលការផ្ទៃក្នុងនិងទម្រង់បែបបទផ្សេងៗរបស់អង្គការសិល្បៈខ្មែរអមតៈ

## ង. ជំនាញនិងបទពិសោធន៍ដែលត្រូវការ

- ត្រូវមានបទពិសោធន៍ការងារនៅក្នុងឬជិតស្និតជាមួយ ក្រសួងអប់រំ យុវជន និងកីឡា
- មានបទពិសោធន៍ធ្វើការក្នុងគ្រឹះស្ថានអប់រំរដ្ឋ
- មានជំនាញក្នុងការចាត់ចែងការងារនិងគ្រប់គ្រងផែនការការងារឲ្យបានច្បាស់ សម្រាប់ក្រុមការងារ និងតាមដានការបំពេញការងាររបស់ពួកគេ
- ចេះបត់បែន ដើម្បីសម្រួលផែនការដែលរៀបចំ ឲ្យស្របទៅនឹងការអនុវត្តជាក់ស្តែង
- ការមានចំណាប់អារម្មណ៍ខាងសិល្បៈនិងវប្បធម៌ និងការមានបទពិសោធន៍ការងារ (ជាលក្ខណៈការងារឬផ្ទាល់ខ្លួន) ជាមួយសិល្បៈ រឹតតែប្រសើរ
- ការធ្វើដំណើរទៅតាមខេត្ត គឺជាចំណុចចំបងរបស់តួនាទីនេះ
- ការមានបទពិសោធន៍ក្នុងការអភិវឌ្ឍន៍កម្មវិធីសិក្សាប្រកបដោយភាពច្នៃប្រឌិត រឹតតែប្រសើរ
- តម្រូវឲ្យចេះភាសាខ្មែរនិងអង់គ្លេសយ៉ាងស្ទាត់ (ទាំងការសរសេរនិងនិយាយ)

## ច. ប្រាក់ខែនិងអត្ថប្រយោជន៍

| | |
|---|---|
| **ប្រាក់ខែពេលចាប់ផ្តើម :** | $១.០០០ - $១,៧០០ (ចំនួនជាក់ស្តែង) អាស្រ័យលើបទពិសោធន៍ |
| **ការវាយតម្លៃការងារ :** | ជាប្រចាំឆ្នាំ នៅក្នុងខែកញ្ញា |
| **អំឡុងពេលសាកល្បង :** | ៣ ខែ |
| **ថ្ងៃសម្រាកប្រចាំឆ្នាំ :** | ១៨ ថ្ងៃ ក្នុង ១ ឆ្នាំ |

## ឆ. អំពីការដាក់ពាក្យ

ដើម្បីដាក់ពាក្យ សូមផ្ញើជីវប្រវត្តិសង្ខេបនិងការពិពណ៌នាសង្ខេបអំពីចំណាប់អារម្មណ៍និងមូលហេតុដែលអ្នកគួរតែត្រូវបានជ្រើសរើសសម្រាប់មុខដំណែងនេះ មកកាន់អ៊ីម៉េល info@cambodianlivingarts.org

ផុតកំណត់ទទួលពាក្យ : ថ្ងៃទី១៣ ខែឧសភា ឆ្នាំ ២០១៨